# មេរៀនទី ១៤០: ហោរាអេលីយ៉ាត្អាល់គ្នាជាមួយពួកហោរាព្រះបាល

## ១ ពង្សាវតារក្សត្រ ១៨:១៦-៤០

**គោលបំណង៖** ព្រះគឺជាព្រះពិតតែមួយ។

**ខគម្ពីរចងចាំ៖ និក្ខមនំ ២០:៣** *"កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវលើកតម្កើងអ្នកដែលដើរតាមទ្រង់។ ការមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវតែងតែទាមទារការលះបង់ ប៉ុន្តែតែងតែនាំមកនូវសន្តិភាព និងទំនុកចិត្ត។ បទគម្ពីរថ្ងៃនេះបញ្ជាក់យ៉ាងច្បាស់ថា វប្បធម៌នៃសម័យកាលនោះ បាននាំមនុស្សជាច្រើនឱ្យឃ្លាតឆ្ងាយពីព្រះពិតតែមួយ ហើយឲ្យដើរតាមព្រះបាលក្លែងក្លាយ។ តើវប្បធម៌របស់អ្នកនាំអ្នកឱ្យឃ្លាតឆ្ងាយពីព្រះដោយរបៀបណា? តើជំនឿ ក្តីសង្ឃឹម និងទស្សនវិជ្ជាជាក់លាក់អ្វីខ្លះដែលព្យាយាមយកមនុស្សចេញពីព្រះ? សូមអធិស្ឋានថាព្រះនឹងនាំអ្នកទៅកាន់កន្លែងដែលអ្នកទុកចិត្តលើទ្រង់ ហើយមានចិត្តដើម្បីបម្រើព្រះតាមរយៈការដឹកនាំការថ្វាយបង្គំនេះ។

**ចំរៀង៖** ១.ព្រះអម្ចាស់យើងល្អណាស់ ២.ព្រះយើងជាព្រះអស្ចារ្យ ៣.ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «បាល់ទះទឹក»



**សម្ភារៈដែលត្រូវការ៖** ប្រកទឹកដាក់ក្នុងប៉េងប៉ោង១ចំនួន ធុងទឹក២ កន្សែង២

១. ចែកកុមារជាពីរក្រុមស្មើគ្នា។

២. ឲ្យក្រុមទី ១ រើសគ្នា៨នាក់ក្នុងការលេងល្បែងនេះ។ ឲ្យកន្សែងពីរទៅក្រុមទី១ពួកគេត្រូវចែកគ្នាជាពីរក្រុមទៀត ដែលម្ខាងមានគ្នា៤នាក់ឈរនៅឆ្ងាយពីគ្នា

៣. គ្រូនឹងដាក់ប៉េងប៉ោងទឹក១ដាក់ក្នុងកន្សែង ហើយពួកគេត្រូវព្យាយាមបោះប៉េងប៉ោងទឹកនោះ ទៅឲ្យគ្នារបស់ពួកគេនៅផ្នែកម្ខាងទៀត។ ប៉ុន្តែក្រុមទី២ ត្រូវឈរនៅចន្លោះកណ្តាល ហើយព្យាយាមចាប់ប៉េងប៉ោងទឹកនោះ។

៤. ពួកគេនឹងទទួលបាន១ពិន្ទុ ប្រសិនបើពួកគេបោះប៉េងប៉ោងបានសម្រេច។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គ្រប់ល្បែងកំសាន្តទាំងអស់តែងតែមានអ្នកឈ្នះ និងចាញ់។ ថ្ងៃនេះយើងនឹងរៀនអំពីការភ្នាល់គ្នារវាងព្យាការីរបស់ព្រះ និងព្យាការីរបស់ព្រះក្លែងក្លាយគឺព្រះបាល។

### ៤. ការណែនាំមេរៀន

បើសិនជាមាននរណាម្នាក់សុំឲ្យអ្នកជ្រើសរើសយកផ្កាក្លែងក្លាយ ឬយកផ្កាពិត តើអ្នកនឹងរើសយកមួយណា? ឬក៏បើមាននរណាម្នាក់ឲ្យអ្នកនូវអាហារក្លែងក្លាយ ឬក៏អាហារពិត ចុះប្រសិនបើមាននរណាម្នាក់ឲ្យលុយក្លែងក្លាយ ឬ

ក៏លុយពិតមកអ្នក តើអ្នករើសយកមួយណា? ថ្ងៃនេះយើងនឹងរៀនពីសាសន៍អ៊ីស្រាអែលដែលបានរើសយកការថ្វាយបង្គំព្រះក្លែងក្លាយ ជំនួសឲ្យការថ្វាយបង្គំព្រះពិត។ តើអ្នកគិតថា អ្នកនឹងជ្រើសរើសមួយណា?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជនជាតិអ៊ីស្រាអែលបានឈប់ថ្វាយបង្គំព្រះ ហើយបានមកថ្វាយបង្គំព្រះក្លែងក្លាយមួយឈ្មោះថាបាល។ នៅពេលនេះជនជាតិអ៊ីស្រាអែលកំពុងរងគ្រោះដោយសារគ្រោះរាំងស្ងួត។ ស្តេចរបស់ជនជាតិអ៊ីស្រាអែលគឺអ័ហាប់ និងភរិយារបស់ទ្រង់យេសេបិលបានគិតថា ព្រះបាលជាព្រះពិត។ ប៉ុន្តែអេលីយ៉ាជាហោរារបស់ព្រះពិតតែមួយបានដឹងថាពួកគេកំពុងតែថ្វាយបង្គំព្រះក្លែងក្លាយហើយ។

ដូច្នេះ គាត់បានហៅប្រជាជនទៅភ្នំកើមែល។ គាត់បានស្នើឲ្យមានការប្រកួតរវាងហោរារបស់ព្រះបាល និងខ្លួនគាត់ដែលជាហោរាតែមួយគត់របស់ព្រះពិត។ លោកបានស្នើឲ្យគេធ្វើអាសនាហើយថ្វាយយញ្ញបូជាដល់ព្រះបាល និងព្រះពិត។ ហើយពួកគេម្នាក់ៗបានសុំឲ្យព្រះរបស់ពួកគេបញ្ជូនភ្លើងទៅដុតគ្រឿងបូជា។

ហោរារបស់ព្រះបាលបានធ្វើគ្រប់យ៉ាងដែលពួកគេអាចធ្វើបាន។ បន្ទាប់ពីគេសុំព្រះបាលហើយ គេក៏ស្រែកហើយរាំ។ ពួកគេថែមទាំងបានធ្វើឲ្យខ្លួនឯងរងរបួស ដើម្បីបង្ហាញថាពួកគេច្បាស់លាស់ប៉ុណ្ណា ប៉ុន្តែពួកគេមិនបានទទួលអ្វីសោះ។ ព្រះរបស់ពួកគេមិនបានបញ្ជូនភ្លើងមកទេ។ ព្រះបាលគឺជាព្រះក្លែងក្លាយ។

បន្ទាប់មកជាវេនរបស់អេលីយ៉ា។ អេលីយ៉ាបានសង់អាសនាថ្វាយព្រះពិតតែមួយ។ ប៉ុន្តែអេលីយ៉ាបានធ្វើឲ្យលំបាកសម្រាប់ខ្លួនគាត់ ដើម្បីឲ្យមនុស្សអាចដឹងថាអ្នកណាជាព្រះពិតតែមួយ។ គាត់បានជីកគូបទឹកជុំវិញអាស-នារបស់គាត់ ហើយចាក់ទឹកពេញលើយញ្ញបូជា។ គាត់បានប្រើទឹកច្រើនរហូតដល់ទទឹកឈើ ហើយពេញគូបទឹកដែលនៅជុំវិញអាសនា។ អេលីយ៉ាបានសុំព្រះពិតតែមួយដងឲ្យដុតគ្រឿងបូជា។ ព្រះបានចាត់ភ្លើងឲ្យឆេះគ្រឿងបូជា ឈើ ថ្មដែលធ្វើអាសនា ដីនៅក្រោមអាសនា និងទឹកដែលពេញគូបទឹកនោះ។

ក្រោយពីបានឃើញសកម្មភាពដ៏អស្ចារ្យរបស់ព្រះពិតតែមួយ ជនជាតិអ៊ីស្រាអែលនឹកចាំថា ព្រះរបស់ពួកគេគឺជាព្រះពិតតែមួយ។ ពួកគេបានដឹងថាខ្លួនត្រូវបានគេបោកបញ្ឆោត ដោយអ្វីមួយដែលមើលទៅត្រឹមត្រូវ ប៉ុន្តែគ្មានអំណាច។ ព្រះគម្ពីរប្រាប់យើងថាព្រះគឺជាព្រះអម្ចាស់ជាព្រះនៃយើង ហើយយើងនឹងមិនមានព្រះឯទៀតនៅចំពោះទ្រង់ឡើយ។

ពេលខ្លះលោកីយ៍ព្យាយាមប្រាប់យើងថាមានអ្វីមួយដែលមានឥទ្ធិពល ឬល្អជាងព្រះ។ ប៉ុន្តែយើងត្រូវចាំថាព្រះបានបង្កើតអ្វីៗគ្រប់យ៉ាងក្នុងលោកីយ៍នេះ។ គ្មានអ្វីដែលមានឥទ្ធិពល ឬល្អជាងអ្នកបង្កើតឡើយ។ ព្រះនៃយើងគឺជាព្រះពិតតែមួយ ដែលគួរតែត្រូវបានគេគោរពប្រណិប័តន៍!

## ៦. សំនួរពិភាក្សា

១. តើព្រះក្លែងក្លាយមួយណាដែលជនជាតិអ៊ីស្រាអែលថ្វាយបង្គំ? *ព្រះបាល*

២. តើអ្វីជាការប្រជែងរវាងអេលីយ៉ា និងហោរាក្លែងក្លាយរបស់ព្រះបាល?

*គេនឹងថ្វាយយញ្ញបូជា ហើយសុំព្រះរបស់ពួកគេបញ្ឆេះយញ្ញបូជានោះឲ្យឆេះ*

៣. តើព្រះបាលបានធ្វើអ្វីខ្លះ ពេលហោរារបស់ព្រះបាលអធិស្ឋានដល់ទ្រង់? *គ្មានធ្វើអ្វីទេ*

៤. ហេតុអ្វីបានជាព្រះបាលមិនធ្វើអ្វីសោះ? *ព្រោះគាត់ជាព្រះក្លែងក្លាយ គាត់មិនមែនជាព្រះទេ*
៥. តើព្រះបានធ្វើអ្វីពេលអេលីយ៉ាអធិស្ឋានទៅទ្រង់?*ទ្រង់បានបញ្ជូនភ្លើងដ៏ខ្លាំងមកដុតគ្រឿងបូជាឈើថ្មទឹក*
៦. តើនរណាជាព្រះពិតតែមួយ? *ព្រះរបស់យើងគឺជាព្រះពិតតែមួយ!*

## ៧. ល្បែងកំសាន្ត «ព្រះពិតតែមួយ»



**សម្ភារៈដែលត្រូវការៈ**ក្រមាពណ៌ខុសៗគ្នាពីរ (ឬក៏ក្រដាស) សម្រាប់តំណាងឲ្យ "ព្រះពិតតែមួយ" និង "ព្រះក្លែងក្លាយ"

១. ឲ្យកុមារទាំងអស់ឈរជាជួរនៅខាងចុងនៃថ្នាក់រៀន។ (លេងនៅខាងក្រៅថ្នាក់ក៏បាន)

២. នៅពេលដែលគ្រូលើកសញ្ញា "ព្រះពិតតែមួយ" ហើយនិយាយថា"ខ្ញុំជឿលើព្រះពិតតែមួយ" កុមារត្រូវដើរទៅមុខ។ ប្រសិនបើកុមារណាមិនដើរ ពួកគេនឹងចាញ់ល្បែងនេះ។

៣. នៅពេលដែលគ្រូលើកសញ្ញា "រូបព្រះក្លែងក្លាយ" ហើយនិយាយថា "ខ្ញុំជឿលើរូបព្រះក្លែងក្លាយ" នោះកុមារគ្រប់រូបមិនត្រូវដើរនោះទេ។ ប្រសិនបើមានកុមារណាដើរពួកគេនឹងចាញ់ល្បែងនេះ។

៤. គ្រូគួរតែផ្លាស់ប្តូរពាក្យពី "ព្រះពិតតែមួយ" ទៅជា"រូបព្រះក្លែងក្លាយ" ឲ្យបានឆាប់ ដើម្បីឲ្យកុមារពិបាកក្នុងការធ្វើតាម។

៥. កុមារណាដែលអាចទៅប៉ះជញ្ជាំងបានមុនគេ នោះគេនឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គឺមានព្រះពិតតែមួយប៉ុណ្ណោះ ហើយយើងរស់នៅគឺសម្រាប់តែព្រះអង្គផងដែរ។

## ៨. ខគម្ពីរចងចាំ និក្ខមនំ ២០:៣

## ៩. ហត្ថកម្ម ផាត់ពណ៌ «អេលីយ៉ាសុំភ្លើង»





**សម្ភារៈដែលត្រូវការៈ** បោះពុម្ពក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ



១. កាត់បន្ទាត់ត្រង់ចំនុចចុចៗនៅលើក្រដាសហត្ថកម្មនោះ។

២. កាត់អណ្តាតភ្លើង និងប្រអប់ជាមួយគ្នា។

៣. ផាត់ពណ៌អេលីយ៉ា អាសនា និងអណ្តាតភ្លើង។

៤. កាត់ផ្នែកខាងលើនៃអាសនាជារាងចតុកោណកែង ដើម្បីឱ្យវាអាចរំកិលឡើងលើចុះក្រោមបាន។

៥. សូមពន្យល់កុមារថា ព្រះមានអំណាចធ្វើអ្វីៗទាំងអស់ រួមទាំងការដុតភ្លើង និងដុតលើយញ្ញបូជា និងអាសនាដែលជ្រលក់ក្នុងទឹក។ ព្រះរបស់យើងគឺជាព្រះពិតតែមួយ!

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*



